**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
**MINISTRY OF INFORMATION**
លេខ......៤៩៧.........ព.ម សរ

រាជធានីភ្នំពេញ, ថ្ងៃទី..០១.....ខែតុលា....ឆ្នាំ២០១៨

# សារាចរ
## ស្តីពី
## ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង

បច្ចុប្បន្ននេះផលប៉ះពាល់អវិជ្ជមានជាច្រើនដែលទាក់ទងដល់បញ្ហាសុខភាព ការបង្កបួសស្នាម គ្រោះថ្នាក់ចរាចរ អំពើហិង្សាក្នុងគ្រួសារ ភាពក្រីក្រៗលៗ គឺមួយចំណែកបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង។ រាជរដ្ឋាភិបាល បានដាក់ចេញនូវវិធានការនានាជាបន្តបន្ទាប់សំដៅកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង ប៉ុន្តែទន្ទឹមនេះ ក្រសួងព័ត៌មាន នៅតែពិនិត្យឃើញថាការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនៅតាមប្រព័ន្ធផ្សព្វផ្សាយនានាក្នុងប្រទេសមាន អាហ្វីស ប៉ាណូ កាសែត ទស្សនាវដ្តី វិទ្យុ និង ទូរទស្សន៍ ជាពិសេស ទូរទស្សន៍ នៅតែឃោសនាអូសទាញប្រជាពលរដ្ឋឱ្យសេពគ្រឿងស្រវឹងដើម្បីឈ្នះយករង្វាន់ ឬ សេពគ្រឿងស្រវឹងនាំមកនូវក្តីសប្បាយរីករាយថ្វាអារម្មណ៍ ឬ តាមរូបភាពផ្សេងៗទៀតធ្វើឱ្យមានការភ័ន្តច្រឡំអំពីការសេពគ្រឿងស្រវឹង។

ដើម្បីរួមគ្នាការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ សុវត្ថិភាពសង្គម កាត់បន្ថយផលអវិជ្ជមានខាងលើដែលបណ្តាលមកពីការសេពគ្រឿងស្រវឹង ក្រសួងព័ត៌មាន ចេញបទបញ្ជាសម្រាប់ការផ្សាយគ្រឿងស្រវឹងជាពិសេសការផ្សាយតាមស្ថានីយទូរទស្សន៍ ទូរទស្សន៍ខ្សែកាប និង វិទ្យុ FM ទាំងអស់ដូចខាងក្រោម ៖

១. ចាប់ពីថ្ងៃចេញសារាចរនេះតទៅរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ នៅរៀងរាល់វេលាម៉ោង១៨:០០នាទី ដល់ម៉ោង២០:០០នាទី រាល់ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងគឺតម្រូវឱ្យផ្សាយតែ Logo ផលិតផល និង អក្សរជាឈ្មោះផលិតផលតែប៉ុណ្ណោះ ឬ អានឈ្មោះផលិតផល ហើយស្ពតពាណិជ្ជកម្មត្រូវហាមឃាត់។

២. ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅនៅរៀងរាល់វេលាម៉ោង១៨:០០នាទី ដល់ម៉ោង២០:០០ នាទី គឺពុំអនុញ្ញាតជាដាច់ខាតឱ្យផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងទេ ទោះជាការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនោះភ្ជាប់ជាមួយកម្មវិធីព័ត៌មាន ការប្រគុំតន្ត្រី ការប្រកួតកីឡា ការកំសាន្ត បទចម្រៀង KARAOKE ដែលឧបត្ថម្ភដោយក្រុមហ៊ុនផលិត ឬ ចែកចាយគ្រឿងស្រវឹងក៏ដោយ។

៣. បណ្តាក្រុមហ៊ុនផលិត ឬ ចែកចាយគ្រឿងស្រវឹងទាំងអស់ចាប់ពីពេលនេះតទៅក្នុងការផលិតស្ពតពាណិជ្ជកម្មត្រូវយកចិត្តទុកដាក់លើកខ្លឹមសារ និង រូបភាព ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានទាំងឡាយដូចខាងលើ គិតគូរដល់សុវត្ថិភាពសង្គម និង ប្រយោជន៍ដល់ប្រជាពលរដ្ឋ។

៤. គ្រប់ប្រព័ន្ធឃោសនាទាំងអស់ចាប់ពីពេលនេះតទៅត្រូវបន្តអនុវត្តដោយម៉ឺងម៉ាត់សេចក្តីណែនាំរបស់ក្រសួងព័ត៌មាន លេខ១៣៩ ព.ម ចុះថ្ងៃទី០២/កុម្ភៈ/២០១០ សេចក្តីណែនាំលេខ១៧៦០ ព.ម ចុះថ្ងៃទី០៩/ធ្នូ/២០១១ និង សេចក្តីណែនាំលេខ១៤២៧ ព.ម ចុះថ្ងៃទី០៨/តុលា/២០១២ ស្តីពីការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង។

ក្រសួងព័ត៌មាន នឹងធ្វើការត្រួតពិនិត្យមើលការអនុវត្តសារាចរនេះ ករណីរំលោភមិនអនុវត្ត ក្រសួងព័ត៌មាន នឹងធ្វើការដកហូតអាជ្ញាប័ណ្ណ ផ្អាកការធ្វើអាជីវកម្មប្រព័ន្ធផ្សព្វផ្សាយ ហើយក្រុមហ៊ុនផលិត ឬ ចែកចាយគ្រឿងស្រវឹងនោះ នឹងត្រូវហាមឃាត់មិនឱ្យធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មបន្តទៅទៀតតាមប្រព័ន្ធឃោសនាឡើយ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

- សមាគមវិទ្យុកម្ពុជា
- សមាគមទូរទស្សន៍កម្ពុជា
- គ្រប់សមាគមអ្នកកាសែត
- គ្រប់ប្រព័ន្ធឃោសនា
- គ្រប់ក្រុមហ៊ុនផលិត ឬ ចែកចាយគ្រឿងស្រវឹង

"ដើម្បីអនុវត្ត"